# ព្រឹត្តិប័ត្រ សាឡេស៊ាន កម្ពុជា

ព្រឹត្តិប័ត្រសាឡេស៊ានឆ្នាំទី២

ខែ មករា ឆ្នាំ ២០២២

Khmer Salesian Bulletin



## ពួកយើង បានត្រឡប់ មករៀន នៅសាលា វិញហើយ!

សម្ព័ន្ធ បរិស្ថាន ដុនបូស្កូ

Don Bosco GREEN ALLIANCE

# ចម្រៀង យុវជន

## ១ យើងជាយុវជនយុវនារី

I. (ប្រុស) យើងជាយុវជន ជាកូនលោកពុកបូស្កូ មកពីបច្ចិមប្រទេស ស្គាល់លោកពុកបូស្កូ ក្លាយជាយុវជនគំរូ របស់លោក។

* (រួម) ៖ តើពុកបូស្កូជានរណា? នោះយើងមកស្គាល់ទាំងអស់គ្នា? តើលោកបានធ្វើអ្វីខ្លះ? ម្ដេចបានជាមានលោកពុក ជាមនុស្សបែបណា បានជា គេស្រលាញ់។

II. (ស្រី) ៖ យើងជាយុវនារី ក៏ជាកូនពុកបូស្កូដែរជីវិតយើងបានប្ដូរប្រែ ដោយមានពុកជាគំរូ គឺលោកពុកបូស្កូ ជា បិតា យុវជន.

R. (ប្រុស) ៖ យើងជាយុវជន មិនភ្លេចគុណពុកបូស្កូ ត្រូវធ្វើខ្លួនជាពលរដ្ឋគំរូ អោយបានដូចពុកបូស្កូ ទោះបីជាគាត់មិននៅក៏ដោយ។

R2. (ស្រី) ៖ យើងយុវជននារី ជាកូនពុកបូស្កូផងខិតខំមិនអោយពុកខកបំណង ជាទំពាំងស្នងឫស្សី មិនត្រូវការអ្វី ក្រៅពីដួងចិត្ត។

III.(ប្រុស) ៖ យើងជាយុវជន (ស្រី)៖ យើងជាយុវនារី រួមគ្នាផ្សាយដំណឹងល្អ ទឹកចិត្តដ៏សប្បុរស របស់លោកពុក ធ្វើឱ្យកូន មានក្ដីសុខ ខាងចិត្ត វិញ្ញាណ។

## ៣ ជូនបូស្កូមិត្តខ្ញុំ

I. ដុនបូស្កូអើយ អ្នកហើយជាផ្ទះខ្ញុំ ជាផ្ទះមួយដ៏ធំ សម្រាប់ខ្ញុំ និងយុវជនគ្រប់គ្នា ជាកន្លែងមិនរងារ មានភាពកក់ក្ដៅ...

II. ដុនបូស្កូអើយ អ្នកប្រៀនប្រដៅខ្ញុំ ឱ្យក្លាយជាមនុស្សរម្យទម្យ ក្លាយជាមនុស្សល្អ ក្លាហាន ហ៊ឺ...ដុនបូស្កូអើយ អ្នកគឺមិត្តខ្ញុំ ។

R. ឱ! មិត្តខ្ញុំអើយ អ្នកជាមនុស្សល្អ មានចិត្តសប្បុរស ដល់មនុស្សគ្រប់គ្នា មេត្តាករុណា ក្មេងៗគ្រប់គ្នា គ្រប់ពេលវេលា លោកតែង គិតដល់. ។

III. ដុនបូស្កូអើយ អរគុណអ្នកខ្លាំងក្រៃ រាល់គ្រប់ជំនាញអ្វី លោកតែងបង្ហាត់ បង្រៀនឱ្យចេះ ហ៊ឺ...ពួកខ្ញុំស្រលាញ់ លោកពុកបូស្កូ ។

## ២ អនុស្សាវរីយមហាគ្រួសារ

I. អនុ ស្សាវរីយ កាលយើងទាំងអស់រស់នៅ ជុំគ្នា មកពី ខេត្តនានា រស់ជុំគ្នា ជាគ្រួសារឃ្លាតឆ្ងាយពីពុកម្ដាយ និងស្រែចំការ ដើម្បីមកសិក្សា សាងអនាគតថ្មី ។

II. រួមសុខ រួមទុក្ខ រួមរស់ដូចបងដូចប្អូន តែមួយ ចេះយក អាសាជួយ មានទុក្ខព្រួយ ក៏មិនភ័យ ខិតខំ សិក្សា ទាំងប្រុស ទាំងស្រី ទោះជាពិបាកក្ដី ក៏នៅ តស៊ូ ។

R. សូមព្រះ ជាម្ចាស់តាមថែរក្សា ដល់មហាគ្រួសារ របស់យើងខ្ញុំ អោយចេះរួបរួមគ្នា បន្តជួយអោយថ្កើងថ្កុំ អភិវឌ្ឍ គ្រួសារ អោយធំ លើលោកា ។

III. អនុ ស្សាវរីយ៍ មហាគ្រួសារដ៏ធំ យើងអើយ បំភ្លេចមិនបានឡើយ គ្រួសារអើយ ចាំគ្រប់គ្រា បានផ្ដល់ក្ដីស្រលាញ់ បងប្អូនគ្រប់គ្នា ប្រៀបដូចពុកបូស្កូ លោកជាគំរូ ដ៏ល្អ ។

## ៤ អរគុណជូនបូស្កូ

I. មើលផ្ទៃសមុទ្រ រលើកនឹករឿងអតីត ខ្សែជីវិតក៏វិតឱ្យជួបភាពក្រ ប្រឹងប្រែងតស៊ូ ផ្លាច់ប្ដូរដើម្បីវិជ្ជា ទោះខ្សត់ទ្រព្យា ខិតខំពុះពារ ព្រោះ ចង់សិក្សា ។

II. ជាសំណាងល្អ បានចូលរៀនសាលាល្អ ដុនបូស្កូជួយសិស្សក្រីក្រ ទាំងឡាយ ខ្ញុំ ត្រូវខំរៀនឱ្យចេះ មិនឱ្យអ្នកខកចិត្តឡើយ ដុនបូស្កូអើយ សូមអ្នកជួយផ្ដល់ កំលាំងចិត្ត ផង ។

R. ខ្ញុំ... ខ្ញុំសូមប្ដេជ្ញា ខ្ញុំត្រូវខំសិក្សាឱ្យបានល្អ រៀន...ដើម្បីអនាគត រៀន... ក៏ដើម្បី កេរ្តិ៍ឈ្មោះសាលា ចង់ប្រាប់ថា... ខ្ញុំរីករាយក្រៃ ព្រោះតែមានថ្ងៃ បានដុនបូស្កូ ជួយខ្ញុំ គ្រប់គ្រា ។

III. ដុនបូស្កូអើយ អ្នកជាដង្ហើមនៃជីវិតខ្ញុំ ហើយក៏ជាអ្នកមានគុណ សិស្សទាំងឡាយ ខ្ញុំតំណាងឱ្យសិស្ស ទាំងអស់ខ្ញុំទាំងសាលា សូមផ្ដាំប្រាប់ថា យើងខ្ញុំគ្រប់គ្នា អរគុណអ្នក ណាស់ ។

# មាតិកា


១. អត្ថន័យនៃ៨មិនា ទិវាសិទ្ធិនារី

២. ព្រះអំណោយទានឆ្នាំ ២០២២

៣. ប្រវត្តិបងប្រុស គង់ សុមុនី

៤. ក្បាច់គុន ប្រដាល់សេរី

៥. សិស្សចាស់ ដុនបូស្កូ

៦. សន្ត ហ្វ្រង់ស័រ ដឺសាល

៧. ចម្រៀងយុវជន

៨. ប្រវត្តិបងប្រុស អេង សារ៉ាង

៩. ទំព័ ចងចាំសាឡេស៊ាន សន្ត សន្តី

១០. សាររបស់អគ្គមហាធិការ លោកឪពុក អ៊ែនហេល

១១. រឿងលោកពុក បូស្កូ តុក្កតា

១២. សាររបស់លោកឪពុក ជីដាស់ សឺអូ

១៣. ព័ត៌មាន ដុន ដូស្កូ កម្ពុជា

១៤. ប្រវត្តិបងប្រុស ប្រាក់ អៀត

១៥. ពិធីសច្ចានិរន្ត របស់បងប្រុស គង់ សុមុនី និង បងប្រុស រ៉េម៉ុន

១៦. បេសកកម្ម បងស្រីកាម៉ែល

១៧. គ្រួសារ សាឡេស៊ាន ដុនបូស្កូ

១៨. ត្រីផ្សោតនៅកម្ពុជា

១៩. វិហារឧទ្ទិសដល់ សន្ត ដូមិនិក សាវីយ៉ូ

២០. ព្រះនាងម៉ារីជាទីពំនឹងមកពីណា?

២១. ក្មេងស្រី ឡអូរ៉ា វីកូញា

២២. មកស្គាល់បុគ្គលបរិសុទ្ធសាឡេស៊ានដំបូង

២៣. ជំនាញឱជីថលមូលដ្ឋានសម្រាប់សាឡេស៊ាន

២៤. អធិដ្ឋានដល់ប្រទេសអ៊ុយក្រែន

២៥. លោកអាកាស ប្តូរជីវិតដើម្បីមិត្តភក្តិ














**ទិវា**នារីអន្តរជាតិ គឺជារឿងរបស់នារីសាមញ្ញម្នាក់ ដែលជាអ្នកកសាងប្រវត្តិសាស្ត្រ។ វាបានចាក់ឫសក្នុងការតស៊ូរបស់នារីអស់ពេលរាប់សតវត្ស ដើម្បីចូលរួមក្នុងសង្គមដោយស្មើភាពជាមួយបុរស។ ថ្ងៃទី៨ មីនា គឺជាទិវាអន្តរជាតិនៃសិទ្ធិនារី ដែលបច្ចុប្បន្នត្រូវបានគេ ប្រារព្ធធ្វើឡើងជាទូទៅក្នុងពិភពលោកយើង។ ទិវានេះ គឺជានិម្មិតរូបនៃការតស៊ូ ទាមទារ សិទ្ធិសេរីភាពរបស់ស្ត្រី ប្រឆាំងនឹងការរើសអើងផ្លូវភេទព្រមទាំងអសមភាពទាំងអស់រវាងបុរសនិងស្ត្រី។ មុននឹងមានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិ រហូតសព្វថ្ងៃនេះ គឺមានការតស៊ូប្រឹងប្រែង អស់ប្រមាណមួយសតវត្ស ពីសំណាក់សកម្មជន ដើម្បីឱ្យមានការផ្លាស់ប្តូរផ្នត់គំនិតសង្គមក្នុងការទទួលស្គាល់សិទ្ធិរបស់ស្ត្រី។

## ប្រវត្តិនៃការតស៊ូ រហូតធ្វើឱ្យមាន ទិវាសិទ្ធិនារីអន្តរជាតិ( ៨មីនា )

ការតស៊ូទាមទារសិទ្ធិស្ត្រី ទំរាំតែមានទិវាអន្តរជាតិ ៨មីនានេះ មិនមែន ធ្វើតែមួយថ្ងៃបាននោះទេ។ វាគឺជាលទ្ធផល នៃការតវ៉ា ទាមទាររបស់សកម្មជន អស់រយៈពេលរាប់សិបឆ្នាំ បន្តិចម្តងៗ ទំរាំតែមានថ្ងៃនេះ។ កាលពីដើមសតវត្សទី២០ លក្ខខណ្ឌរស់នៅ របស់ស្ត្រីនៅទូទាំងពិភពលោក មានការលំបាកណាស់។

នៅចុងសតវត្សទី១៩ បច្ចេកវិជ្ជា បានរីកចម្រើន ជាពិសេសនៅសហរដ្ឋអាមេរិកនិងបណ្តាប្រទេសដែលមានឿនឧស្សាហកម្មរីកចម្រើន។ នារី និងកុមារក្រីក្រារាប់លាននាក់ ត្រូវបានចូលធ្វើការនៅក្នុងរោងចក្រសហគ្រាសឯកជននានាទាំងឡាយ។ ពួកម្ចាស់រោងចក្រសហគ្រាសមួយចំនួន មានគំនិតលោភលន់ កេងប្រវ័ញ្ចបង្ខំឲពួកគេធ្វើការជាទម្ងន់ក្នុងមួយថ្ងៃពី១២ម៉ោងទៅ១៦ម៉ោង ហើយផ្តល់ប្រាក់បៀវត្សតិចតួចបំផុត ដោយមិនគិតពីសុខភាពរបស់កម្មករឡើយ។

ដោយការឈឺចាប់ចំពោះអំពើកៀបសង្កត់កេងប្រវ័ញ្ចហួសប្រមាណនោះ នៅថ្ងៃទី៨ មិនា ឆ្នាំ១៨៩៩ កម្មការីនីផ្នែកតម្បាញ និងកាត់ដេរនៅទីក្រុងស៊ីកាហ្គោ និងញូយ៉ក សហរដ្ឋអាមេរិកបានសាមគ្គីឯកភាពគ្នាក្រោកឈរឡើងរស៊ូទាមទារឱ្យបន្ថយម៉ោងធ្វើការ និងដំឡើងប្រាក់បៀវត្ស។ ប៉ុន្តែជាលទ្ធផលកម្មការីនីទាំងនោះត្រូវបានទទួលការកៀបសង្កត់ចាប់ចងធ្វើទារុណកម្ម និងត្រូវបណ្តេញចេញពីរោងចក្រ។

ទោះបីត្រូវទទួលការឈឺចាប់ កម្មការីនីនៅតែសាមគ្គីគ្នាតស៊ូស្វិតស្វាញម្តងហើយម្តងទៀត។ ចលនាដ៏ស្វិតស្វាញនេះបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើនារីពលករនៅប្រទេសអាឡឺម៉ង ដែលជាប្រទេសឧស្សាហកម្មធំមួយនាសម័យនោះ។



ក្មេងៗទទួលកាដូក្នុងថ្ងៃ៨មិនា

ឆ្នាំ១៩១០ សន្និបាតអន្តរជាតិនារីដែលមានប្រទេស១៧ចូលរួមបានធ្វើឡើងនៅទីក្រុងកូប៉ែនហាក រដ្ឋធានីនៃប្រទេសដាណឺម៉ាក បានសម្រេចយកថ្ងៃ៨មិនា ទិវានារីអន្តរជាតិ ថ្ងៃមហាសាមគ្គីតស៊ូរបស់នារីពលករទូទាំងសាកលលោក ដើម្បីសិទ្ធិសេរីភាពប្រជាធិបតេយ្យដោយភ្ជាប់ជាមួយនឹងពាក្យស្លោកថា «មួយថ្ងៃធ្វើការប្រាំបីម៉ោង» «ធ្វើការស្មើគ្នា បៀវត្សស្មើគ្នា» «ការពារសុខភាពមាតា និងទារក»។ ចាប់តាំងពីថ្ងៃនោះមក ថ្ងៃ ៨ មិនា បានក្លាយទៅជា ថ្ងៃបុណ្យអន្តរជាតិនារី ដែលរំឭកអំពីការតស៊ូរបស់នារីពលករទូទាំងសកលលោក គឺដោយសារតែមានកិច្ចប្រឹងប្រែងដោយអំណត់ ព្យុះពារ និងការលំបាកគ្រប់បែបយ៉ាងពី១០០ឆ្នាំមុននេះហើយ ទើបបច្ចុប្បន្ននេះ នារីក្នុងពិភពលោកមានឱកាសទទួលបាននូវសិទ្ធិស្មើភាពក្នុងការបន្តុះបង្អាប់ខ្លះៗក៏ដោយ។

ជាបន្ទាប់ ចលនានារីអន្តរជាតិ បានខិតខំដោះស្រាយបញ្ហានារី ដែលនៅសល់ តាមរយៈការស្នើឡើងទៅអង្គការសហប្រជាជាតិដោយសន្និសីទនារីជាច្រើនលើកច្រើនសា។ នៅឆ្នាំ ១៩៧៥ សន្និសីទពិភពលោករបស់នារីលើកទី១ បានធ្វើឡើងនៅទីក្រុងមិចស៊ិចកូ ប្រទេសមិចស៊ិចកូ ក្រោមប្រធានបទ «សមភាព វឌ្ឍនភាព និងសន្តិភាព»។

ផែនការសកម្មភាពដែលបានសម្រេចនៅពេលនោះ គេបានអំពាវនាវឱ្យមានការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនិងនារីភេទ និងរៀបចំទម្រង់ការដ៏មានប្រសិទ្ធិភាពសម្រាប់អនុម័តអនុសញ្ញានេះ។ ខែតុលា ឆ្នាំ ១៩៧៥ ដដែល អង្គការសហប្រជាជាតិបានប្រកាសថាពីឆ្នាំ ១៩៧៦ ដល់ ១៩៨៥ ជាសតវត្សសម្រាប់នារី។ នៅឆ្នាំ១៩៨០ សន្និសីទពិភពលោកលើកទី២ របស់នារីបានធ្វើឡើងនៅទីក្រុងកូប៉េនហាក ប្រទេសដាណាម៉ាក់។

នៅឆ្នាំ១៩៨៥ ចុងបញ្ចប់នៃទសវត្សនារី គេបានរៀបចំសន្និសីទលើកទី៣ម្តងទៀតនៅទីក្រុងណៃរ៉ូប៊ី ប្រទេសខេនញ៉ា ដើម្បីពិនិត្យ និងវាយតម្លៃលើលទ្ធផលសម្រេចរបស់ទសវត្សនារីព្រមទាំងធ្វើការអនុម័តលើយុទ្ធវិធីចម្រើនទៅមុខសម្រាប់ភាពលូតលាស់របស់នារីក្នុងឆ្នាំ២០០០។ ចុងក្រោយនេះ គឺឆ្នាំ១៩៩៥ពីថ្ងៃទី១៥ កញ្ញា អង្គការសហប្រជាជាតិបានរៀបចំសន្និសីទនារីពិភពលោក លើកទី៤ នៅទីក្រុងប៉េកាំ សាធារណរដ្ឋប្រជាមានិតចិន។ ប្រធានបទជាគោលគឺ «សមភាព វឌ្ឍនភាព និងសន្តិភាព» បើយើងប្រៀបធៀបប្រវត្តិទិវាអន្តរជាតិនារី ៨ មិនា ទៅនឹងកំណើតនៃអង្គការសហប្រជាជាតិ ឃើញថា ប្រវត្តិទិវាអន្តរជាតិ ៨មិនា មានកំណើតមុនអង្គការសហប្រជាជាតិទៅទៀត។ ហើយក៏មានកំណើតមុនសិទ្ធិមនុស្សទៀតផង។

តែទោះជាយ៉ាងនេះក៏ដោយ សព្វថ្ងៃនៅកម្ពុជា ពិតមែនតែមានច្បាប់ជាតិ ច្បាប់អន្តរជាតិ ដូចជា សេចក្តីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិស្តីពីអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនិងនារីភេទ និងរដ្ឋធម្មនុញ្ញគ្រង់ជំពូក៣ ដែលស្តីពីសិទ្ធិ នោះហើយក៏ដោយវិសមភាពរវាងបុរសនិងស្ត្រី ការរើសអើង ប្រឆាំងនឹងនារីភេទ ការរំលោភសិទ្ធិស្ត្រី ហិង្សាក្នុងគ្រួស នៅតែកើតមានជាបញ្ហា។ ហេតុនេះហើយបានជារាជរដ្ឋាភិបាលខំប្រឹងខ្នះខ្នែងយកបញ្ហាដើម្បីជួយស្ត្រីឱ្យមានភាពយុត្តិធម៌ក្នុងការទទួលសិទ្ធិ និងប្រើសិទ្ធិដើម្បីជួយកាត់បន្ថយ ទប់ស្កាត់លុបបំបាត់ចោលនូវបញ្ហា ទាំងឡាយខាងលើដែលមានចំពោះស្ត្រីភេទ។

# លោកពុក លី សំណាង ពន្យល់អំពី

# ព្រះអំណោយទាន ឆ្នាំ ២០២២




រាល់ឆ្នាំ លោកឪពុកធំនៅទីក្រុងរ៉ូម គឺលោកពុក អ៊ែនហេល ហ្វាណាន់ដេស អធីមេ ជាអ្នកដែលដឹកនាំដុនបូស្កូ ទាំងមូលលើពិភពលោក ។ លោកបានឱ្យសារមួយសម្រាប់យើងបានចែកនៅគ្រប់កន្លែងគឺយើងហៅសារនេះថា "ព្រះអំណោយទាន" គឺជាអ្វីដែលមកពីព្រះគម្ពីរជាប្រវត្តិសាស្ត្រដុនបូស្កូ ។ នៅឆ្នាំនេះ លោកពុកធំ អ៊ែនហេល បានជ្រើសរើសពាក្យមួយដែល សន្ត ហ្វ្រង់ស្វ័រ ដឺសាល ពន្យល់សម្រាប់យើងទាំងអស់គ្នា ។ សន្ត ហ្វ្រង់ស្វ័រ ដឺសាល ជាបូជាចារ្យ អភិបាលម្នាក់ដែលរស់ប្រហែល២០០ឆ្នាំមុនលោកពុកបូស្កូ ។




សន្ត ហ្វ្រង់ស័រ ដឺសាល រស់នៅប្រទេសបារាំង កន្លែងដែលគាត់កំណើតជាប្រទេសតូច ។ គាត់បាននិយាយថា "ធ្វើអ្វីដោយសេចក្តីស្រលាញ់ គ្មានការបង្ខិតបង្ខំ" មានន័យថា អ្វីៗទាំងអស់ដែលយើងធ្វើត្រូវបង្ហាញដោយសេចក្តីស្រលាញ់ ហើយលោកពុកបូស្កូ យកសារនេះសម្រាប់ការអប់រំសាឡេស៊ាន សម្រាប់សាលារបស់លោកពុកនៅលើពិភពលោកទាំងមូល ។ លោកពុកបូស្កូយកគំនិតនេះ សម្រាប់យើងធ្វើការអប់រំសម្រាប់ក្មេង និងយុវជនយុវនារី ដូច្នេះហើយ យើងធ្វើអ្វីទាំងអស់ ការបង្រៀនពោរពេញទៅដោយសេចក្តីស្រលាញ់ ។

ឧទាហរណ៍ៈ នៅក្នុងសាលាមានវិន័យ តែវិន័យនោះមិនជាវិន័យដែលបង្ខិតបង្ខំយើង ។ យើងធ្វើទាំងនេះ សម្រាប់ការពារយុវជន សម្រាប់ការពារក្មេង សម្រាប់ការពារលោកគ្រូអ្នកគ្រូ ក្នុងនាមសេចក្តីស្រលាញ់ ។ នៅក្នុងព្រះអំណោយទាននោះគឺ ធ្វើអ្វីទាំងអស់ដោយសេចក្តីស្រលាញ់ដោយគ្មានការបង្ខិតបង្ខំ គឺជាអ្វីដែល សន្ត ហ្វ្រង់ស្វ័រ ដឺសាល បង្រៀន ហើយត្រូវបានលោកពុក បូស្កូ យកមកសិក្សានៅសាឡេស៊ាន ។ យើងមានរូបភាព លោកពុក បូស្កូ នៅក្នុងព្រះអំណោយទាន និងក្រោយពុកបូស្កូ មានសន្ត ហ្វ្រង់ស្វ័រដឺសាល គាត់ជាអ្នកអោយគំនិតលោកពុកបូស្កូ ។ នៅខាងមុខពុកបូស្កូ មានបេះដូង ហើយបេះដូងនោះជាបេះដូងរបស់លោក ពុកបូស្កូផ្ទាល់ ។ នៅក្នុងបេះដូងនោះ មានយុវជនយុវនារីជាច្រើន ដែលមានបេសកកម្មរបស់លោកពុកបូស្កូ ។ នៅខាងឆ្វេងមានព្រះនាងម៉ារីជាទីពំនឹងជាមួយកុមារព្រះយេស៊ូ ។



នេះជាសញ្ញាសំខាន់សម្រាប់ឆ្នាំ២០២២ ។ យើងមើលឃើញមានសញ្ញាមួយ ជាសញ្ញាចង្វាក់បេះដូង មានន័យថាយើងដើរទៅមុខជានិច្ចដោយសេចក្តីស្រលាញ់ ។ សរុបមកពាក្យខាងលើ "ធ្វើអ្វីដោយសេចក្តីស្រលាញ់ ដោយគ្មានការបង្ខិតបង្ខំ" ជាពិសេសសម្រាប់លោកគ្រូ អ្នកគ្រូ នៅពេលបង្រៀន ដឹកនាំ និងអប់រំ សម្រាប់យុវជន យុវនារី និងសម្រាប់ក្មេង និងយុវជនដែលធ្វើអ្វីទាំងអស់ជាមួយសេចក្តីស្រលាញ់ដូចជា ការរៀនដោយសេចក្តីស្រលាញ់ ការធ្វើការងារដោយសេចក្តីស្រលាញ់ រួមគ្នាទាំងអស់ សប្បាយជាមួយគ្នា ធ្វើការជាមួយទាំងអស់ដោយសេចក្តីស្រលាញ់ អត់មានអ្នកណា មកបង្ខិតបង្ខំយើងធ្វើអ្វីទេ ។






# ប្រវត្តិជាអ្នកបួស របស់បងប្រុស គង់ សុមុនី



ឈ្មោះពេញរបស់ខ្ញុំ **គង់ សុមុនី** ហៅកាត់ថា បងប្រុស **សុមុនី** មកពីខេត្តពោធិ៍សាត់ មានអាយុ ៣៦ ឆ្នាំ រៀនបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យនៅខេត្តពោធិ៍សាត់។ ខ្ញុំកើតនៅ ថ្ងៃទី០៥ មិថុនា ឆ្នាំ១៩៨៥ នៅជំរុំជនភៀសខ្លួនព្រំប្រទល់ ខ្មែរ-ថៃ។ ខ្ញុំមានបងប្អូនបួននាក់ ប្រុសបីនាក់ និងស្រីមួយនាក់ ហើយខ្ញុំជាកូនទីពីរ។

នៅឆ្នាំ១៩៩២ ក្រុមគ្រួសារខ្ញុំបានធ្វើមាតុភូមិនិវត្តត្រលប់មករស់នៅស្រុកកំណើតរបស់ម្តាយខ្ញុំនៅខេត្តពោធិ៍សាត់។

នៅជំរុំជនភៀសខ្លួន ខ្ញុំបន្តរៀននៅខេត្តពោធិ៍សាត់រហូតបញ្ចប់ថ្នាក់ទី១២។ នៅឆ្នាំ ២០០២ ខ្ញុំមកប្រលងចូលរៀននៅដុនបូស្កូដោយសារបានទទួលដំណឹងពីមិត្តភក្តិម្តាយខ្ញុំដែលជាកាតូលិក ព្រោះនៅព្រះសហគមន៍ក៏មានយុវជនខ្លះត្រៀមនឹងទៅប្រលងចូលរៀននៅសាលាដុនបូស្កូភ្នំពេញ ខ្ញុំក៏ចូលរួមជាមួយពួកគេដែរ តែខ្ញុំមិនមែនជាកាតូលិកទេ ហើយក៏មិនដែលស្គាល់ព្រះសហគមន៍កាតូលិកដែរ។

ខ្ញុំចូលមកនៅ ដុនបូស្កូ តាំងពីឆ្នាំ២០០២ មកដល់ពេលនេះ មានរយៈពេល ១៩ ឆ្នាំ ហើយ។ ២ឆ្នាំជាសិស្សដុនបូស្កូភ្នំពេញ ៥ឆ្នាំ ជាគ្រូបង្រៀននៅដុនបូស្កូប៉ោយប៉ែត ២ឆ្នាំ រៀនភាសាអង់គ្លេសនៅប្រទេសហ្វីលីពីន។ ៦ឆ្នាំរៀនជាបងប្រុស និងរៀនទស្សនៈវិជ្ជានៅប្រទេសថៃ។ ៤ឆ្នាំត្រលប់មកជាបងប្រុសនៅប្រទេសកម្ពុជា ។

បច្ចុប្បន្នកំពុងរៀនទេវវិទ្យាល័យឆ្នាំទី១ នៅប្រទេសហ្វីលីពីន។ ក្រោយបានចូលរៀននៅសាលាដុនបូស្កូ បានទទួលការអប់រំច្រើន ទាំងចំណេះដឹងទូទៅ ជំនាញបច្ចេកទេស និងជំនឿសាសនាខាងកាតូលិករហូតបានទទួលអគ្គសញ្ញាជ្រមុជទឹក។

ការសម្រេចចិត្តនេះ បានធ្វើឡើងតាំងពីមុនទទួលការបួសកាលពីឆ្នាំ២០១៣មក។ មុនពេលសម្រេចចិត្តចូលរៀនបួសនៅក្នុងក្រុមគ្រួសារសាឡេស៊ាន ខ្ញុំធ្លាប់បានចូលរួមស្វែងយល់ពីការត្រាស់ហៅក្នុងក្រុម អេម៉ាណូអែល ជិត ២ឆ្នាំ ដែរ។

# វិធីបរិច្ចាក តាមគណនេយ្យ វីង មកកាន់ដុនបូស្កូកម្ពុជា









1 ជាដំបូងចូលទៅគណនេយ្យ Wing របស់អ្នក បន្ទាប់មកស្វែងរកពាក្យថា bill payment.

2 ចូលទៅកាន់ OTHERS បន្ទាប់មកជ្រើសរើស Don Bosco Foundation of Cambodia (USD)

3 **បំពេញលេខ code "0" ចំនួន12ខ្ទង់រួមទាំងលេខសាខា រួចជ្រើសរើស ដុនបូស្កូ ណាមួយដែលអ្នកចង់ផ្ញើរ**

- **សម្រាប់ Don Bosco Phnom Penh សូមវាយលេខ "1"**
- **សម្រាប់ Don Bosco Sihanoukville សូមវាយលេខ "2"**
- **សម្រាប់ Don Bosco Battambang សូមវាយលេខ "3"**
- **សម្រាប់ Don Bosco Poipet សូមវាយលេខ "4"**
- **សម្រាប់ Don Bosco Kep សូមវាយលេខ "5"**

**បន្ទាប់មកចំនួនលុយ ដែលអ្នកចង់បរិច្ចាគ**




Wing

4

**ចុចលើពាក្យ Pay**

**បន្ទាប់មកយកពាក្យ Confirm ជាការស្រេច**



# ប្រដាល់សេរី ឬ ក្បាច់គុនខ្មែរ
## ជាគុនរបស់ខ្មែរតាំងពីបុរាណ



ប្រដាល់សេរី ឬ គុនខ្មែរ ជាសិល្បៈក្បាច់គុន ជាកីឡាប្រយុទ្ធដោយគ្មានអាវុធ និងជាក្បាច់គុនដែលហាត់ដោយមនុស្សវ័យក្មេង។ ឈ្មោះផ្លូវការរបស់កីឡានេះគឺ ក្បាច់គុនប្រដាល់ខ្មែរ។ កីឡានេះ មានការក្រោកឈរ និងវាយសម្រុក ដែលមានគោលបំណងវាយគូរប្រកួត បង្ខំឲ្យសន្លប់តាមបច្ចេកទេស ឬឈ្នះការប្រកួតដោយពិន្ទុ។

ប្រដាល់សេរី ត្រូវបានគេស្គាល់ច្រើនតាមរយៈបច្ចេកទេស ទាត់ កែង។ ប្រដាល់សេរី មានវាយ៤ប្រភេទគឺ កណ្តាប់ដៃ ទាត់ កែង និងជង្គង់។ ស្នៀតនេះត្រូវបានប្រើសំរាប់វាយគូប្រកួត។ ក្នុងការប្រកួត គូរប្រកួតប្រដែងដណ្ដើមយកទីតាំងលេចធ្លោ សំរាប់ការវាយក្នុងចម្ងាយខ្លីដោយកែង និងជង្គង់។ អ្នកប្រដាល់កម្ពុជា និយមប្រើស្នៀតកែងច្រើនជាងក្បាច់គុនផ្សេងទៀតក្នុងតំបន់។ នៅក្នុងប្រដាល់សេរី ជ័យជម្នះកាន់តែច្រើនកើតឡើង ដោយបច្ចេកទេសកែងជាងការវាយផ្សេងទៀត។

ប្រដាល់សេរីចាប់ផ្តើមពីអាណាចក្រខ្មែរ ហើយអាណាចក្រខ្មែរ បានបង្កើតឡើងក្នុងឆ្នាំ ៨០២ នៃគ.ស ក្នុងពេលដែលប្រទេសនៃអាស៊ីអាគ្នេយ៍សម័យទំនើបជាច្រើន មិនទាន់មាននៅឡើយ។ ក្បាច់គុន ត្រូវបានយោធាអាណាចក្រខ្មែរប្រើ។ ប្រដាល់សេរី មានឫសគល់មកពីការប្រយុទ្ធដោយដៃអនុវត្តដោយយោធាអាណាចក្រខ្មែរនៅសម័យអង្គរ មានប្រដាប់អាវុធ និងគ្មានអាវុធ។ ភ័ស្តុតាងបង្ហាញថា រចនាបថដែលស្រដៀងនឹងប្រសាទសិរី មាននៅសតវត្សទី៩ ដែលអាចជាហេតុផលមួយ ដែលធ្វើឱ្យអាណាចក្រខ្មែរ ក្លាយជាមហាអំណាយោធានៅអាស៊ីអាគ្នេយ៍។



អាណាចក្រខ្មែរ បានប្រើទម្រង់ដើមនៃប្រដាល់សេរី រួមជាមួយនឹងអាវុធផ្សេងៗ និងដំរីចម្បាំង ដើម្បីធ្វើសង្គ្រាមប្រឆាំងនឹងសត្រូវ។ នៅពេលនោះ អាណាចក្រខ្មែរបានត្រួតត្រា និងគ្រប់គ្រងភាគច្រើនជាប្រទេសកម្ពុជា ឡាវ ថៃ និងផ្នែកខ្លះនៃវៀតណាម។ ប្រទេសកម្ពុជាបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើវប្បធម៌ ថៃ និងឡាវ។ នេះនាំឱ្យខ្មែរអះអាងនូវទម្រង់ប្រដាល់អាស៊ីអាគ្នេយ៍ទាំងអស់ដែលបានចាប់ផ្តើមដោយជនជាតិមន-ខ្មែរដំបូង។ សេចក្តីថ្លែងការណ៍នេះ គឺជារឿងផ្ទាល់មាត់ពីបុព្វបុរសរបស់ពួកគេ និងបន្ថែមជាមួយនឹងចម្លាក់លៀនស្រាល ចម្លាក់ថ្ម នៅតាមប្រាសាទបុរាណ (ប្រាសាទបាយ័ន បន្ទាយឆ្មារ និងប្រាសាទអង្គរ) ផ្សេងទៀត ដែលបង្ហាញពីអត្ថិភាពនៃប្រជាជាតិជិតខាង។ ការសរសេរជាច្រើននៅលើសិល្បៈខ្មែរបុរាណ ត្រូវបានបំផ្លាញដោយកងទ័ពថៃ ដែលឈ្លានពាន នៅពេលដែលសៀមបានបណ្តេញចេញ និងប្លន់អង្គរ។ ក្នុងសម័យអាណានិគម ក្បាច់គុនដូចជា ប្រដាល់សេរី ត្រូវបានអាណានិគមអឺរ៉ុប ចាត់ទុកថា ជាក្បាច់គុនឃោរឃៅ និងគ្មានសីលធម៌។

ជនជាតិបារាំង បានប្រែក្លាយសិល្បៈនេះ ទៅជាកីឡាមួយដោយបន្ថែមសង្វៀនប្រដាល់ និងស្រោមដៃប្រដាល់កាត់បន្ថយការរបួស។ ដើមឡើយការប្រកួតត្រូវបានវាយប្រយុទ្ធគ្នា ដែលមានច្បាប់កំណត់ខណៈពេលដែលដៃត្រូវបានរុំដោយខ្សែព្រ។ ការប្រកួតមួយចំនួនមានអ្នកប្រដាល់ រុំសៃលហ្វី ជុំវិញកណ្តាប់ដៃរបស់ពួកគេដើម្បីកាត់បន្ថយការខូចខាតដែលរងរបួស។ ការប្រកួតបញ្ចប់ដោយការស្លាប់មិនមែនជារឿងចម្លែកទេ។ នៅទសវត្សរ៍ឆ្នាំ ១៩៦០ អ្នកផ្សព្វផ្សាយប្រដាល់កម្ពុជា បានប្រារព្ធពិធីតាំងពិពណ៌សិល្បៈក្បាច់គុន។



# សិស្សចាស់ជុំនបួស្តួ



កញ្ញា **ហោង សូនិច**
ធ្វើការនៅ ទស្សនាវដ្ដីប្រជាប្រិយ

នាងខ្ញុំ **ហោង សូនិច** ជាសិស្សជំនាន់ទី០៨ នៃផ្នែកទំនាក់ទំនង និងប្រព័ន្ធផ្សព្វផ្សាយ។ មូលហេតុមកសិក្សានៅទីនេះ ដោយសារតែជំនាញមួយនេះវាមានទីផ្សារកាងារច្រើន។ ហើយនាពេលបច្ចុប្បន្ន កំពុងធ្វើការនៅ Popular Magazine (ទស្សនាវដ្ដី ប្រជាប្រិយ) ។

ជំនាញដែរខ្ញុំធ្វើ គឺខាងកាត់តវីដេអូ និងកាមេរ៉ា។ ចំពោះផលវិបាកវិញ គឺដោយសារការចូលធ្វើការលើកដំបូងខ្ញុំមិនយល់ច្បាស់ក្រុមហ៊ុនការងារ។ ម្យ៉ាងវិញទៀត ជាបទពិសោធន៍លើកដំបូងអ្វីៗដែលថ្មីចំពោះបទពិសោធន៍ការងារវិញអាចថាពីការងារមួយទៅការងាមួយយើងតែងតែជួបអ្វីដែរថ្មីៗ យើងយល់ដឹងច្រើនពីការងារហើយយើងក៏អាចរៀនសូត្របានជាច្រើននៅកន្លែងធ្វើការ។

មួយវិញទៀតធ្វើការនៅ Popular Magazine ទទួលបានការអប់រំជាច្រើនក៏ដូចជាការណែនាំ និងការអភិវឌ្ឍន៍ខ្លួនពីមួយជំហានបន្ថែមទៀត។ ជាចុងក្រោយខ្ញុំសូមសំណូមពរ ឲ្យសិស្សប្អូនខិតខំរៀនសូត្រជាពិសេសត្រូវចាប់ជំនាញអ្វីដែលខ្លួនស្រឡាញ់ខិតខំរៀនដោយយកចិត្តទុកដាក់ថាពេលយើងចេញធ្វើការគឺមិនដូចយើងនៅសាលាទេយើងត្រូវជួបអ្វីដែរយើងមិនធ្លាប់ជួបពីមុន។ ចំពោះការងារវិញបើសិនយើងមិនច្បាស់លាស់នៅជំនាញដែលយើងកំពុងធ្វើនោះវានិងផ្ដល់ផលវិបាកខ្លាំងនៅពេលយើងចេញទៅធ្វើការហេតុដូច្នេះត្រូវមានការខិតខំរៀនសូត្រនឹងចាប់យកជំនាញណាមួយដែលយើងស្រឡាញ់និងចង់ធ្វើនៅពេលអនាគត។

---



កញ្ញា **អ៊ិន ចន្ថា**
ធ្វើការនៅ អប្សរា មេឌៀ

នាងខ្ញុំ **អ៊ិន ចន្ថា** ជាសិស្សជំនាន់ទី០៧ នៃផ្នែកទំនាក់ទំនង និងប្រព័ន្ធផ្សព្វផ្សាយ។ មូលហេតុដែលខ្ញុំរៀនផ្នែកនេះ ដោយសារតែខ្ញុំចូលចិត្តមើលភាពយន្ត ហើយពេលមើលម្ដងៗ តែងតែចង់ដឹងចង់ចេះដូចជាគេ។ បច្ចុប្បន្ន ខ្ញុំកំពុងបម្រើការងារនៅ Apsara Media Services (AMS) មានទីតាំងនៅ ព្រែកលាប រាជធានីភ្នំពេញ មានតួនាទីជាអ្នក Assistant Porducer ។

ផលវិបាកដែលបានជួបគឺមិនសូវជាមានច្រើនទេពីព្រោះខ្ញុំតែងតែសិក្សាស្វែងយល់ពីក្រុមការងារនៅជុំវិញខ្លួនជានិច្ច។ ចំណែកឯបទពិសោធន៍ក៏មិនសូវជាមានច្រើនដែរ ដោយសារតែបានការងារនៅខាងកាត់វិដេអូរយៈពេញ២ឆ្នាំ ហើយក៏បានផ្លាស់ប្ដូរមកធ្វើនៅកន្លែងបច្ចុប្បន្ននេះឯង។ ជាសំណូមពរដល់សិស្សប្អូនជំនាន់ក្រោយៗគឺត្រូវតែខិតខំប្រឹងប្រែងសិក្សារៀនសូត្រ ឧស្សាហ៍ព្យាយាមធ្វើនូវអ្វីដែលខ្លួនស្រលាញ់ និងអ្វីដែលខ្លួនកំពុងធ្វើដោយភាពត្រឹមត្រូវ និងចេញពីចិត្ត ។

ខ្ញុំបាទ ឈ្មោះ **កែវ សុខហោង** ដែលមានទីកន្លែងកំណើតនៅស្រុក កំពង់ត្រាច ខេត្តកំពត។ មុនដំបូងដែលបានមកសិក្សានៅ សាលាបច្ចេកទេស ដុន បូស្កូ ខេត្តកែប ផ្នែកប្រព័ន្ធផ្សព្វផ្សាយ និងសារព័ត៌មាន។ សាលានេះ បានបណ្តុះបណ្តាលនូវជំនាញជួយទៅដល់យុវជនឱ្យមានជំនាញពិតប្រាកដ ដែលអាចចេញធ្វើការមានប្រាក់ខែសមរម្យ អាចជួយកសាងសេដ្ឋកិច្ចគ្រួសារ ក៏ដូចជាកសាងសេដ្ឋកិច្ចប្រទេសជាតិផងដែរ។ មុននឹងមកសិក្សានៅទីនេះ គឺខ្ញុំទទួលបានព័ត៌មាន តាមរយៈវិទ្យុ ហ្វេសប៊ុក។ ពេលមកដល់សាលា គឺពិតជាស្រស់ស្រាយ ។



លោក **កែវ សុខហោង**
ធ្វើការនៅ ទូរទស្សន៍ប៉ុស្តិ៍លេខ៥

ចំពោះការសិក្សានៅទីនេះ ដោយសារនៅទីនេះ គឺឆ្នាំទីមួយ ផ្តោតទៅលើទ្រឹស្តី៧០% និងអនុវត្ត ៣០%។ ហើយបន្ទាប់ពីនោះ ពេលចូលឆ្នាំទីពីរវិញ គឺទ្រឹស្តីតែ ៣០% ចំណែកឯអនុវត្ត ៧០% គឺយើងអនុវត្តជាក់ស្តែងតែម្តង។ លោកគ្រូ អ្នកគ្រូនៅទីនេះ គឺបណ្តុះបណ្តាលយើងឲ្យមានសម្តតភាពអាចធ្វើការបាន នៅពេលដែលយើងបញ្ចប់ការធ្វើសារណានៅសាលា។ គឺសាលាបានបណ្តុះបណ្តាលយុវជនជាច្រើនប្រមាណជាង ១០០០នាក់ ហើយទទួលបានការងារល្អមួយ ទាំង ស្ថាប័នរដ្ឋ និងឯកជន។

សព្វថ្ងៃ ធ្វើការនៅ ស្ថានីយ៍ទូរទស្សន៍កងយុទ្ធពលតូមិន្ទ ប៉ុស្តិ៍លេខ៥ ។ ខ្ញុំបានចូលទៅធ្វើការនៅទីនោះ កាលឆ្នាំ ២០១៦ ខែសីហា រហូតមកដល់ពេលនេះអស់រយៈពេល ៥ឆ្នាំ ហើយ។ ហើយជំនាញរបស់ខ្ញុំ គឺសរសេរពិត័មាន ថតរូប អ្នកកាត់ត។ ហើយថ្មីៗនេះ បានបន្ថែមការងារមួយទៀត គឺការផលិតស្ពតពាណិជ្ជកម្ម។ ដោយឡែកនៅទីនោះ ខ្ញុំបានទទួលទៅលើការថត សម្ភាសន៍ កាត់តវីដេអូ វីដេអូពិត័មាន វីដេអូសម្ភាសន៍ និងវីដេអូប្រូម៉ូតហាង ផ្ទះ ឬដីឡូតិ៍ និងផ្សេងៗទៀត។

ចំពោះផលវិបាកគឺមាន គ្រាន់តែវាតិច ឬច្រើនទៅតាមទីកន្លែង។ ពេលខ្លះចេញទៅសម្ភាសន៍ ទៅតាមប្រភពទីកន្លែង ប៉ុន្តែបែជាមិនបានទៅវិញ ឬក៏ប្រភពរបស់យើងមិនសហការ។ ពេលខ្លះចំពោះកាត់តវីដេអូរបស់យើងនៅពេលយប់ព្រលប់លើសម៉ោងតិចតួច និងមេស្តិបន្ទោសជាដើម។ តែនេះវាជាទូទៅហើយ នៅកន្លែងធ្វើការងារ គឺតែងមានមេស្តីបែបហ្នឹងហើយ តែយើងអាចដោះស្រាយវាបាន។ ការធ្វើការងនៅកន្លែងនោះ គឺដើម្បីការអភិវឌ្ឍន៍សមត្ថភាពខ្លួនបន្ថែមទៀត ដើម្បីត្រៀមខ្លួនទៅធ្វើការងារនៅកន្លែងផ្សេងៗទៀត ពីព្រោះយើងមិនមែននៅធ្វើការតែមួយកន្លែងទេ។ ហើយក៏មិនមែននៅធ្វើការតែមួយជំនាញដែរ គឺត្រូវតែមានការអភិវឌ្ឍន៍សមត្ថភាពឱ្យបានច្រើន ដើម្បីទៅថ្ងៃអនាគតអាចបើកអាជីវកម្មខ្លួនឯង។ ជាការណែនាំដល់សិស្សប្អូនជំនាន់ក្រោយៗ គឺត្រូវតែខិតខំសិក្សា និងក្រេបយកចំណេះដឹង ពីលោកគ្រូ អ្នកគ្រូ ឱ្យបានច្រើន ជាពិសេសគឺលោកពុក លី សំណាង គឺយើងទទួលបាននូវទ្រឹស្តីមួយចំណែក និងការអនុវត្តនៅក្រុមហ៊ុន ដែលយើងបានទៅធ្វើការ និងទទួលបាននូវប្រាក់ខែសមរម្យសម្រាប់ចិញ្ចឹមជីវិត។

# រំលឹកខួប ៤០០ឆ្នាំ ការស្លាប់របស់ សន្ត ហ្វ្រង់ស័រ ដឺសាល

លោកឪពុកអាធិការធំ បានជ្រើសរើសប្រយោគមួយដោយសន្ត ហ្វ្រង់ស័រ ដឺសាល សម្រាប់ព្រះអំណោយទានឆ្នាំ២០២២ " ធ្វើគ្រប់យ៉ាងដោយសេចក្តីស្រលាញ់ មិនមានអ្វីជាការបង្ខិតបង្ខំ"។ ប្រយោគ ដែលបន្តនូវភាពខាងវិញ្ញាណរបស់ លោកអភិបាល នៃទីក្រុងហ្សឺណែវ ហើយបានបំផុសគំនិតដល់បេសកកម្មរបស់ សន្តយ៉ូហាន បូស្កូ និងការអភិវឌ្ឍបេសកកម្មរបស់គ្រួសារសាឡេស៊ានជុំវិញពិភពលោក។

ប្រាកដណាស់ សន្ត ហ្វ្រង់ស័រ ដឺសាល អាចមិនស្គាល់សូម្បីតែក្រុមមួយចំនួនដែលទាក់ទងនឹងដុនបូស្កូក៏ដោយ ។ នៅក្នុងប្រទេសកម្ពុជា មជ្ឈមណ្ឌលអប់រំ និងគ្រូអប់រំភាគច្រើន ត្រូវបានគេហៅថា "សាលាដុនបូស្កូ" ផ្ទុយពីប្រទេសផ្សេងទៀត ដែលពួកគេត្រូវបានគេហៅថា " សាលាសាឡេស៊ាន " នោះមិនមែនជាបញ្ហាទេ ពីព្រោះឈ្មោះរបស់ ដុន បូស្កូ គឺស្របច្បាប់ទាំងស្រុង ប៉ុន្តែវាជាកាតព្វកិច្ចរបស់យើង ក្នុងការធ្វើឱ្យមើលឃើញនូវតួរលេខរបស់ សន្ត ហ្វ្រង់ស័រ ដឺសាល ដែលជាគាំទ្រនៃ គ្រួសារសាឡេស៊ាន និងពួកបរិសុទ្ធដែលកាន់កាប់កន្លែងដ៏ធំមួយនៅក្នុងអ្នកក្បត់សាសនា ។ មូលដ្ឋានគ្រឹះនៃ ដុន បូស្កូ មិនត្រឹមតែនៅក្នុងទឹកដីនៃការអប់រំប៉ុណ្ណោះទេ ប៉ុន្តែក៏មាននៅក្នុងការបង្កើតស្មារតីសាឡេស៊ានផង។



## ឆ្នាំដំបូងរបស់គាត់ គ្រួសារ និងការបង្កើត

ហ្វ្រង់ស័រ ដឺសាល កើតមុនអាយុ ២ ខែ នៅថ្ងៃទី ២១ ខែសីហា ឆ្នាំ ១៥៦៧ នៅក្នុង ប្រាសាទរបស់សាលនាពេលបច្ចុប្បន្ននេះ នៅទីក្រុង តូរេន-គ្លារេ ប្រទេសបារាំង នៅពេលនោះ នៅក្នុងរដ្ឋដែលផុតពូជនៃ ឌុចនៃសាវូយ ។ គាត់បានកើតនៅក្នុងគ្រួសារអភិជនមួយ៖ ឪពុករបស់គាត់គឺ ហ្វ្រង់ស័រ លោកម្ចាស់នៃសាល និង បូអ៊ីសី ។ ម្តាយរបស់គាត់គឺ ហ្វ្រង់សី ដឺសីអូណាស កូនស្រីរបស់ចៅក្រម លោកមេលជាអូរ ដឺសីអូណាស លោកម្ចាស់ ដឺវ៉ាលាអេរ ដឺឡាទូអ៊ីលេ និង ដឺពូអ៊ីសី ។ គាត់គឺជាកូនប្រុសដំបូងក្នុងចំណោមកូនប្រុស ៦នាក់ ហើយជាការពិតណាស់ ឪពុករបស់គាត់ចង់បានការអប់រំដ៏ល្អបំផុតសម្រាប់ពួកគេ ហើយមាននៅក្នុង ហ្វ្រង់ស័រ ជាចៅក្រមដ៏លេចធ្លោមួយ។

ឆ្នាំនេះគ្រួសារសាឡេស៊ាន ប្រារព្ធខួបលើកទី ៤០០ នៃការស្លាប់របស់ សន្ត ហ្វ្រង់ស័រ ដឺសាល ហើយវាជាឱកាសដ៏ល្អសម្រាប់យើងទាំងអស់គ្នា ដើម្បីឆ្លុះបញ្ចាំងពីអត្ថន័យនៃជីវិតរបស់គាត់ និងនៅក្នុងកេរដំណែលរបស់គាត់ដែលបានដើរតួនាទី និងឥទ្ធិពលដ៏អស្ចារ្យនៅក្នុងព្រះសហគមន៍កាតូលិក ។ ការទំនាក់ទំនងសង្គមកាតូលិកនៅក្នុងការសន្ទនាជាបងប្អូនក្នុងចំណោមសាសនាផ្សេងៗ និងនៅក្នុងមូលដ្ឋានគ្រឹះគ្រួសារសាឡេស៊ាន ដែលនាំមកនូវនាមត្រកូលរបស់ ហ្វ្រង់ស័រ ជាសញ្ញាសម្គាល់អត្តសញ្ញាណ ។ ដើម្បីអបអរសាទរ នៅឆ្នាំ ២០២២ យើងនឹងឃើញការរីកសាយភាយនៃការបោះពុម្ពផ្សាយ ប្រព័ន្ធផ្សព្វផ្សាយ និងការប្រារព្ធពិធីជាច្រើន ជុំវិញបលោក ហ្វ្រង់ស័រ។ មួយគឺការបោះពុម្ពរបស់ លោក អានដ្រេ រ៉ាវីអេរ។



សុភាពបុរសដ៏ល្អឥតខ្ចោះនៃដើមកំណើតដ៏ថ្លៃថ្នូនៃសម័យកាល៖ ឆ្លាតវៃ សង្ហា ខ្ពស់ ភ្នែកពណ៌ខៀវ-ប្រផេះ រក្សា និងស្ងប់ស្ងាត់។ គាត់ជាក្មេងជំទង់ដែលគេស្គាល់ថាជា ហ្វ្រង់ស័រ ដឺសាល។

ជីវិតរបស់ សន្ត ហ្វ្រង់ស័រ ដឺសាល (ជាភាសាបារាំងវាគឺជា (François de Sales) អាចបែងចែកជាបីផ្នែក៖ ទីមួយឆ្នាំដំបូងរបស់គាត់ គ្រួសារ និងការបង្កើត។ ទីពីរ ការប្រែចិត្តជឿ និងបព្វជិតភាពរបស់គាត់ ហើយទីបីគាត់បានក្លាយជាអភិបាល អ្នកនិពន្ធ និងជាស្ថាបនិក។

## ការប្រែចិត្តជឿ

សុភាពបុរសដ៏ល្អឥតខ្ចោះនៃដើមកំណើតដ៏ថ្លៃថ្នូនៃសម័យកាល៖ ឆ្លាតវៃ សង្ហា ខ្ពស់ ភ្នែកពណ៌ខៀវ-ប្រផេះ រក្សា និងស្ងប់ស្ងាត់។ គាត់ជាក្មេងជំទង់ដែលគេស្គាល់ថាជា ហ្វ្រង់ស័រ ដឺសាល។ ប៉ុន្តែព្រះជាម្ចាស់មានគម្រោងផ្សេងទៀតសម្រាប់អភិជនវ័យក្មេងដែលទាន់សម័យ។ អ្វីគ្រប់យ៉ាងបានចាប់ផ្តើមជាមួយនឹងការពិភាក្សាខាងទ្រឹស្តីអំពីការកំណត់ទុកជាមុន គោលលទ្ធិដែលសន្និដ្ឋានថា ព្រឹត្តិការណ៍ទាំងអស់ត្រូវបានប្រាថ្នាដោយព្រះជាម្ចាស់ ជាធម្មតាដោយយោងទៅលើជោគវាសនាចុងក្រោយនៃព្រលឹងបុគ្គល ដែលធ្វើឱ្យគាត់ជឿលើការទទួលទោសរបស់គាត់ទៅឋាននរក។ ដែលអូសបន្លាយពេញខែធ្នូឆ្នាំ ១៥៨៧ ហើយគាត់ថែមទាំងធ្លាក់ខ្លួនឈឺទៀតផង។



ប្រាសាទដឺសាល ប្រាសាទដែលខូចនៅក្នុងឃុំ តូរេន-គ្លារេ នៃប្រទេសបារាំង។ សន្ត ហ្វ្រង់ស័រ ដឺសាល កើតនៅកន្លែងនេះក្នុងឆ្នាំ ១៥៦៧។

# ជូនបូស្ដូមិត្តខ្ញុំ

សរសេរដោយកញ្ញាៈមេន រតនា





I. ដុនបូស្កូអើយ អ្នកហើយជាផ្ទះខ្ញុំ ជាផ្ទះមួយដ៏ធំសម្រាប់ខ្ញុំ និងយុវជនគ្រប់គ្នា ជា កន្លែងមួយមិនរងារ មានភាពកក់ក្តៅ ។

II. ដុនបូស្កូអើយ អ្នកប្រៀនប្រដៅខ្ញុំ ឲ្យក្លាយជាមនុស្សរម្យទម្យ មនុស្សល្អក្លាហាន ហ៊ឺ.. ដុនបូស្កូអើយ អ្នកគឺមិត្តខ្ញុំ ។

R. ឱមិត្តខ្ញុំអើយ អ្នកជាមនុស្សល្អ មានចិត្តសន្តោសដល់មនុស្សគ្រប់គ្នា មេត្តាករុណា ក្មេងៗគ្រប់គ្នា គ្រប់ពេលវេលា គាត់តែងគិតដល់។

III. ដុនបូស្កូអើយ អគុណអ្នកខ្លាំងក្រៃ រាល់គ្រប់ជំនាញអ្វី លោកតែង បង្ហាត់បង្រៀនឲ្យចេះ ហ៊ឺ...ពួកខ្ញុំស្រលាញ់ លោកពុកបូស្កូ ។

# ប្រវត្តិជាអ្នកបួស របស់បង អេង សារ៉េង

ខ្ញុំឈ្មោះ **អេង សារ៉េង** អាយុ ៣២ ឆ្នាំ មកពីខេត្តព្រៃវែង រៀននៅសាលាបច្ចេកទេសដុនបូស្កូ ភ្នំពេញថ្មី។ មូលហេតុចូលមកបួសនៅក្នុងក្រុមគ្រួសារសាឡេស៊ាន ព្រោះខ្ញុំចង់បន្តការងាររបស់ លោកពុកបូស្កូ ជួយយុវជននៅប្រទេសយើង។ ខ្ញុំក៏ត្រូវបានជួយក្នុងការសិក្សាពីថ្នាក់ទី៧ រហូតដល់រៀនចប់ នៅសាលាបច្ចេកទេសដុនបូស្កូភ្នំពេញថ្មី ផងដែរ។



ដូច្នេះ ខ្ញុំចង់ឱ្យយុវជនខ្មែរយើង បានទទួលឱកាសក្នុងការសិក្សាដូចខ្ញុំដែរ។ ខ្ញុំចូលមករស់នៅក្នុងក្រុមគ្រួសារសាឡេស៊ាន ចាប់តាំងពីឆ្នាំ ២០០៩ រហូតដល់បច្ចុប្បន្ន។

ខ្ញុំសម្រេចចិត្តបួសនៅក្នុងព្រះសហគមន៍កាតូលិក ព្រោះខ្ញុំជឿថា ព្រះជាម្ចាស់បានត្រាស់ហៅខ្ញុំ ឱ្យខ្ញុំមានឱកាសធ្វើការតាមព្រះហឫទ័យព្រះអង្គ បានពេញលេញដោយរស់នៅតាមពាក្យសច្ចា រស់នៅតាពក្រីក្រ ព្រហ្មចារីភាព និងការគោរពប្រតិបត្តិ។

ខ្ញុំសម្រេចចិត្តធ្វើជាបងប្រុស។ ដំណើរជីវិតក្នុងការបួស គឺខ្ញុំមានក្ដីសុខតាមលក្ខណៈ ជាបុព្វជិតដោយអនុវត្តតាមពាក្យសច្ចា្យ។ ហើយយើងអធិដ្ឋាន ធ្វើការ និងរស់នៅជាដូចជាគ្រួសារ គឺយើងរស់នៅជាគ្រួសារតែមួយ ទោះបីមកពីប្រទេសផ្សេងៗគ្នា តែយើងរស់នៅជាមួយគ្នាជាគ្រួសារដ៏ធំ ។ ពេលមានទុក្ខលំបាកផ្សេងៗយើងជួយគ្នាទៅវិញទៅមកដូចជាបងប្អូន ព្រោះយើងមានព្រះជាម្ចាស់ជាព្រះបិតា។ សម្រាប់បទពិសោធន៍របស់ខ្ញុំ ការអធិដ្ឋាន មានផលល្អសម្រាប់ការដំណើរជីវិត ហើយក៏ជួយក្នុងការរស់នៅរបស់យើងជាអ្នកបួសក្នុងគ្រួសារសាលេស៊ាន។

# ពួកយើងបានជួយដល់ដុនបូស្កូរួចហើយ

ចុះអ្នកវិញ?

ចូលរួមគាំទ្រ

កុមារ និងយុវជន



# វិធីបរិច្ចាក មកកាន់ មូលនិធិដុនបូស្កូកម្ពុជាតាម អេស៊ីលីដា









# ទំព័រអប់រំ នៃសាឡេស៊ាន

# សន្ត -សន្តី



០៥ តុលា (អាល់លីតម៉ាល់វីលលី)



១៣ តុលា (អាលិចសាន់ដ្រីនណា តា កូសស្តា)



០៥ វិច្ឆិកា (អភិបូជាសម្រាប់ឧបត្ថម្ភអ្នកដែលបានស្លាប់ និងសមាជិកគ្រួសារសាឡេស៊ាន)



២៩ តុលា (ម៉ែខឺល រួ)



១៣ វិច្ឆិកា (ម៉ាហ្គឺតដាលេនណា ម៉ូរ៉ាណូ)



១៥ វិច្ឆិកា (អាទេមី ចាត់ទី)



២៥ វិច្ឆិកា (អភិបូជាសម្រាប់ឪពុកម្តាយរបស់សមាជិតសាឡេស៊ានដុនបូស្កូដែលបានទទួលមរណៈភាព)

# សារ

# របស់លោកពូក អ៊ែន ហោល ហ្វាណាន់ដេស អធីមេ



យើងមើលឃើញថា៖ ពួកគេជាអ្នកកាន់ប្រាជ្ញាជីវិតពិត ទីក្រុងដុនបូស្កូ នៅទីបញ្ចប់បេះដូងរបស់ខ្ញុំត្រូវបានយកឈ្នះដោយបទពិសោធន៍មួយហើយក្រោយមកបានរស់នៅដោយសេចក្តីថ្លៃថ្នូរពិតប្រាកដរបស់ពួកគេ។ ខ្ញុំមិនដឹងថាហេតុអ្វីទេ? ប៉ុន្តែការចងចាំទាំងនេះ ធ្វើឱ្យខ្ញុំដកដង្ហើមខ្យល់បរិសុទ្ធយ៉ាងជ្រៅ។ អ្វីដែលខ្ញុំចែកជូនអ្នកឥឡូវនេះខ្ញុំបានជួបប្រទះប៉ុន្មានថ្ងៃមុននេះ។ ខណៈពេលដែលខ្ញុំកំពុងនិយាយដោយផ្ទាល់នៅទីនេះ ក្នុងទីក្រុងរ៉ូម ជាមួយនឹងខេត្តសាឡេស៊ានរបស់យើង ប្រទេសកូឡុំប៊ីមេដាលលី ។ ការចង់ដឹងចង់ឃើញ ចង់ដឹងថា តើផ្ទះរបស់ពួកគេ "ទីក្រុងដុនបូស្កូ" កំពុងធ្វើអ្វីឥឡូវនេះ? ខ្ញុំបានទៅមើលការងារនោះ ហើយបានជួបយុវជនជាច្រើនគ្រប់ប្រភេទរួមទាំងក្មេងតាមផ្លូវ ដែលបានរួចពីជីវិតនោះ។ ក្នុងឱកាសនោះ ខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំង ចំពោះការជួបជាមួយក្មេងជំទង់កុមារី និងក្មេងប្រុសមួយចំនួន ដែលត្រូវបានជួយសង្គ្រោះពីទ័ពព្រៃ។ ចិត្តខ្ញុំពោរពេញដោយភាពរីករាយដែលបានដឹងថា អតីតទ័ពព្រៃ នៅតែមានវត្តមាននៅក្នុងផ្ទះពីររបស់យើង។

នៅពេលដែលពួកគេត្រូវបានជួយសង្គ្រោះពីកន្លែងដែលពួកគេរស់នៅ (ដោយបង្ខំ ឬដោយឆន្ទៈរបស់ពួកគេ) យុវជនទាំងនេះត្រូវបានបញ្ជូន ប្រសិនបើពួកគេទទួលយកវាទៅផ្ទះសាឡេស៊ាន ដើម្បីចាប់ផ្តើមជីវិតថ្មី។ ខេត្តសាសនាបានប្រាប់ខ្ញុំថាយុវនារីម្នាក់ទើបតែនឹងចូលសកលវិទ្យាល័យ នាងពោរពេញដោយភាពរីករាយ ហើយពិតជាហេតុផលមួយមានអារម្មណ៍ថាមានមោទនភាពរបស់អ្នកអប់រំសាឡេស៊ាន។ អ្វីដែលខ្ញុំនឹកស្មានមិនដល់ថានឹងបានឮ គឺសក្ខីកម្មរបស់យុវនារីម្នាក់នេះ បន្ទាប់ពីពីរបីឆ្នាំនៅក្នុងផ្ទះសាឡេស៊ាន។ ហើយមានអារម្មណ៍ពិតជានៅផ្ទះបានផ្តល់សក្ខីកម្មនេះដល់មន្ត្រីមួយក្រុម ដែលកំពុងមកមើលស្ថាប័នអប់រំរបស់យើង។ ជម្រាបសួរមិត្តភក្តិអ្នកអានព្រឹត្តិប័ត្រសាឡេស៊ានទូស្សនាវដ្តីជាទីគោរពស្រលាញ់ដល់ដួងចិត្តរបស់ដុនបូស្កូ ត្បិតគាត់ជឿថា ការបោះពុម្ពឡើងនេះគឺជាមធ្យោបាយដ៏ល្អបំផុតក្នុងការធ្វើឲ្យគេស្គាល់នូវអំពើល្អទាំងអស់ដែលធ្វើនៅក្នុង វ៉ាលដូកូ ក្នុងណោមក្មេងប្រុសរបស់គាត់ និងនៅកន្លែងផ្សេងទៀតដែលពួកគេព្យាយាមដើម្បីចម្លងជីវិតពួកគេ។ ក្នុងចំណោមចុងក្រោយទាំងនេះជាជំហានដំបូងដែលសាឡេស៊ាន និងបុត្រីម៉ារីជាទីពំនឹងបានធ្វើបេសកម្មនៃប៉ាតាហ្គោនី ។

ថ្ងៃនេះខ្ញុំផ្ញើជូនអ្នកម្តងទៀតដូចខ្ញុំធ្វើរាល់ខែ ជំរាបសួរដោយក្តីស្រលាញ់ និងស្និទស្នាលក្នុងពេលជាមួយគ្នានេះ ខ្ញុំសូមចែករំលែកអ្នកថា ខ្ញុំមានអារម្មណ៍ផ្ទុយគ្នានៅពេលដែលខ្ញុំសរសេរសារនេះសម្រាប់ខែវិច្ឆិកា។ នេះគឺដោយសារតែខ្ញុំចង់និយាយទៅកាន់អ្នកពេលបច្ចុប្បន្ននៃជំងឺរាតត្បាតនេះ ដែលមិនមែនមួយខែមុនទៀតទេ។

ប៉ុន្តែថ្ងៃនេះ ជំងឺរាតត្បាតបានធ្វើឲ្យយើងមានអារម្មណ៍ចំឡែក និងអាក្រក់ពីចម្ងាយ ការមិនទុកចិត្ត និងការភ័យខ្លាចនៃការឆ្លង ទោះបីអ្នកនៅកណ្តាលព្រៃ ហើយគ្មាននរណាម្នាក់នៅក្នុងចម្ងាយ១០០ម៉ែត្រពីអ្នក អញ្ចឹងខ្ញុំក៏ចង់និយាយទៅកាន់មនុស្សចាស់ដែលជាផ្នែកមួយនៃពួកយើងហើយនៅតែឯកោដោយសារតែពួកគេរស់នៅក្បែរយើងតែចំនួនរបស់ពួកគេកើនឡើងកាន់តែច្រើន ហើយដោយសារតែជំងឺរាតត្បាតនេះបានបង្កើតបរិបទដ៏ល្អឥតខ្ចោះ ដើម្បីធ្វើឱ្យពួកគេនៅម្នាក់ឯងកាន់តែច្រើន ដើម្បីឱ្យយើងនៅឆ្ងាយជាងនេះ ឥឡូវនេះនាងបានប្រាប់ពួកគេថា៖ «មើលបានសន្យានឹងទ័ពព្រៃអស់ជាច្រើនឆ្នាំមកហើយថា ខ្ញុំនឹងប្រគល់រូបកាយចិត្ត និងព្រលឹងដល់ពួកគេ ។ ប៉ុន្តែបន្ទាប់មកខ្ញុំបានស្គាល់ ដុនបូស្កូ និងអ្វីៗទាំងអស់ដែលគាត់បន្តធ្វើសម្រាប់ពួកយើង ក្មេងៗ នៅទីនេះនៅក្នុងផ្ទះនេះ។ ហើយខ្ញុំសូមអញ្ជើញយុវជនផ្សេងទៀត ឲ្យលើកយកបុព្វហេតុហើយប្តេជ្ញាខ្លួនយើងឲ្យអស់ពីកម្លាំងចិត្តរបស់យើង។ និយាយមិនចេញ ពីព្រោះខ្ញុំគិតថាខ្ញុំយល់យ៉ាងច្បាស់ពីរបៀបដែលយុវនារីរូបនេះ បានប្រព្រឹត្តនៅពេលមួយចំពោះបុព្វហេតុដែលនាងបានរកឃើញខ្លួនឯង ឬនៅក្នុងការដែលនាងបានជ្រើសរើសចូលរួម បន្ទាប់មកនាងបានរកឃើញថានៅក្នុងផ្ទះសាឡេស្យ៉ាននេះជីវិតអាចខុសគ្នាហើយនាងអាច "ប្រយុទ្ធ" ដោយវិធីមួយផ្សេងទៀតសម្រាប់ហេតុផលតែប៉ុណ្ណោះ ។

ខ្ញុំស្រមៃថា នាងស្រមៃចង់ក្លាយជាអ្នកអាជីព ដ៏អស្ចារ្យម្នាក់ជាភរិយា និងជាម្តាយ។ ដូច្នេះ ខ្ញុំចែករំលែកជាមួយអ្នកដូចដែលខ្ញុំនិយាយទៅកាន់ខ្លួនខ្ញុំ អ្នកអានជាទីស្រលាញ់: មូលហេតុសាមញ្ញទាំងនេះ ជាក់ស្តែង និងកន្លែងពិសេសប្រចាំថ្ងៃ ដែលមិនត្រឹមតែផ្លាស់ប្តូរជីវិតរបស់មនុស្សម្នាក់ប៉ុណ្ណោះទេ ថែមទាំងផ្លាស់ប្តូរសកលលោកនៃជីវិតទាំងមូលរបស់ពួកគេនៅខាងក្នុង ពួកគេបន្តឱ្យមានតម្លៃផងដែរ។ ពេលខ្ញុំនៅ **កាល់គូតា** ទៅសួរសុខទុក្ខបងប្អូនស្រីនៃក្រុមជំនុំមាតា **តេរេសា** ហើយមានឱកាសអធិដ្ឋានក្នុងវិហារដដែល ដែលនាងបានប្រារព្ធពិធីអភិបូជានៅជាប់ផ្នូររបស់នាង និងបានឃើញជនក្រីក្រ ដែលរស់នៅខាងក្រៅទ្វាររង់ចាំបងប្អូនស្រីទាំងនោះ ចេញទៅជួបពួកគេតាំងពីព្រលឹម ដើម្បីមើលថែពួកគេ និងជួយសង្គ្រោះ។ ខ្ញុំសារភាពថា ដំណឹងអាក្រក់ធ្វើឱ្យខ្ញុំធុញទ្រាន់ ព្រោះវាហាក់ដូចជាមានមានដំណឹងតែរឿងអាក្រក់កើតឡើង។ ខ្ញុំស្នើឱ្យយើងចូលរួមជាមួយមនុស្សទាំងនោះដែលចង់បង្កើតតែព័ត៌មានល្អចូលទៅក្នុងការផ្សាយព័ត៌មានតាមទូរទស្សន៍។ អនុញ្ញាតឱ្យយើងចិញ្ចឹមវិញ្ញាណរបស់យើង ជាមួយនឹងអ្វីដែលធ្វើឱ្យយើងដកដង្ហើមយ៉ាងជ្រៅនៃខ្យល់បរិសុទ្ធបរិសុទ្ធ ដូចដែលបានកើតឡើងចំពោះខ្ញុំជាមួយនឹងរឿងរបស់យុវនារីម្នាក់នេះដែលបានរកឃើញថាជីវិតរបស់នាងអាចខុសគ្នា។



# រឿង លោកពុកបូស្កូ



មើលអ្វីដែលបានកើតឡើងនោះចុះ:ប្រសិនបើអ្នកប្រែទៅជាសត្វអ្នកនឹងមានអាកប្បកិរិយាខុសគ្នា។អ្នកនឹងធ្វើវាដោយសុភាពរាបសានិងកម្លាំង។ថ្ងៃណាមួយអ្នកនឹងយល់។
អេ!!! មើលសត្វចៀមទាំងនោះណ៎
??


ប្រទេសអ៊ីតាលីឆ្នាំ ១៨២៤។យើងស្ថិតនៅក្នុងភូមិមួយដែលមានឈ្មោះថា បេកឆេល ដែលមានទីតាំងនៅតំបន់ ប៉ាម៉ុនតេ ។នៅក្នុងផ្ទះចំការមួយ ដែលគ្រួសារ បូស្កូ រស់នៅ ជូអាន កើតកាលពី ៩ ឆ្នាំមុន ជាក្មេងកំព្រាឪពុក ហើយគាត់រស់នៅជាមួយម្ដាយរបស់គាត់ ម៉ាហ្គារីតា បងប្រុសបង្កើតរបស់គាត់ អានទូនី និងគាត់។ បងប្រុស ចូស។
តោះចូលមក ចូស។ យើងទៅមើលគេសម្ដែងសៀក


វាមិនពិបាកទេ។ ខ្ញុំអាចធ្វើបាន
តោះហែកហោប៉ៅរបស់អ្នកដោយ គ្រាន់តែពីរបីនាទីទៀតអ្នកអាចមើលឃើញអ្វីមួយដែលពិបាកបំផុត
ជយោ

# សារលោកឪពុក ជីដាស ស៊ីអូមេនដេស

អត្ថបទទីបីក្នុងចំណោមដប់អត្ថបទប្រចាំខែ ដែលបង្ហាញដោយទីប្រឹក្សាទូទៅនិងទំនាក់ទំនងសង្គម គឺលោកឪពុក **ជីដាស់ស៊ីអូ មេនដេស** លើប្រធានបទ "ដុន បូស្កូ និងឌីជីថល ភាពពិតនិម្មិត" និយាយអំពីទិដ្ឋភាពពិសេសមួយទៀតនៃ ការទំនាក់ទំនងរបស់ សន្ត យុវជនពោលគឺ អំពីរបៀប ដែលគាត់អាចបំផុសគំនិតមនុស្សជាច្រើន ដោយការអភិវឌ្ឍន៍ទំនាក់ទំនងផ្ទាល់ខ្លួនដ៏មានអត្ថន័យ។ នេះជាការឆ្លុះបញ្ចាំងរបស់លោកឪពុក **ជីដាស់ស៊ីអូ មេនដេស។**



"របៀបដែលដុនបូស្កូ បានបំផុសគំនិតមនុស្សយ៉ាងច្រើន និងបង្កើតទំនាក់ទំនងផ្ទាល់ខ្លួន និងមានប្រសិទ្ធភាពក្នុងការអប់រំយុវជន"

ការប្រាស្រ័យទាក់ទង គឺជាសិល្បៈនៃការលើកទឹកចិត្តមនុស្ស។ អ្នកប្រាស្រ័យទាក់ទងល្អ គឺជាអ្នកដែលបង្កើតទំនាក់ទំនងផ្ទាល់ខ្លួន និងមានប្រសិទ្ធភាពជាមួយអ្នកដទៃ។

ការប្រាស្រ័យទាក់ទងគ្នា តែងតែទាមទាពីការទាក់ទងនូវសមត្ថភាពដ៏អស្ចារ្យក្នុងការទំនាក់ទំនង និងបង្កើតចំណងជាមួយមនុស្ស មិនថាតាមវិទ្យុ ទូរទស្សន៍ អ៊ីនធើណិត កាសែត ការបង្រៀន ការអធិប្បាយទេ អ្នកប្រាស្រ័យទាក់ទងត្រូវមានវត្តមានយកឈ្នះការបញ្ចុះបញ្ចូល រក្សាភាពស្មោះត្រង់ ។

នៅក្នុងពិភពឌីជីថល និងការពិតនិមិត្ត ការទំនាក់ទំនងគឺជាមូលដ្ឋានគ្រឹះនៃវិធីទំនាក់ទំនងរបស់យើង។ តាមរយៈទំនាក់ទំនង យើងបង្កើតវត្តមាននៅក្នុងជីវិតរបស់មនុស្ស។ វត្តមានសិល្បៈនៃប្រាស្រ័យទាក់ទងគ្នា មិនត្រឹមតែបច្ចេកទេស ល្បិចកល ប៉ុណ្ណោះទេ វាជាមធ្យោបាយដ៏ប៉ិនប្រសប់។

ដើម្បីឱ្យនរណាម្នាក់ មានវត្តមានជាមួយនឹងអាកប្បកិរិយានៃការបំផុសគំនិត និងបង្កើតភាពជឿជាក់នេះ អារម្មណ៍ គំនិត ទឹកមុខ អាកប្បកិរិយារបស់ពួកគេត្រូវការភាពស៊ីសង្វាក់គ្នា។ ការចុះសម្រុងគ្នានេះត្រូវតែស្របតាមតម្លៃដែលពួកគេជឿជាក់ និងបទពិសោធន៍។




ក្រឡេកមើលពីចិត្តសាស្ត្រនៃសុបិនដ៏សំខាន់នេះ បានបង្ហាញពីវត្តមានរបស់ យ៉ូហាន បូស្កូ យ៉ាងខ្លាំងចំពោះអារម្មណ៍របស់គាត់ក្នុងការចូលរួមយ៉ាងពេញទំហឹងក្នុងការសន្ទនាជាមួយបុគ្គលិកលក្ខណៈដ៏ថ្លៃថ្នូរ។ មានភាពស៊ីសង្វាក់គ្នា រវាងពាក្យនិយាយ និងរូបភាពដែលលេចឡើងក្នុងសុបិនរបស់គាត់។ ដុន បូស្កូ  គឺជាអ្នកប្រាស្រ័យទាក់ទងដែលតែងតែនិយាយចេញពីបទពិសោធន៍ខាងក្នុងរបស់គាត់អំពីព្រះជាម្ចាស់ ពិតជាមានភាពស៊ីសង្វាក់គ្នានៅក្នុងបេសកកម្មដែលព្រះជាម្ចាស់បានប្រទានដល់គាត់ ឱ្យស្រលាញ់ និងយកចិត្តទុកដាក់ចំពោះក្មេងៗ។ ការបើកបេះដូងរបស់គាត់ចំពោះព្រះគុណ  និងសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់   និងទីបន្ទាល់របស់គាត់ អំពីមនុស្សជាតិ និងភាពបរិសុទ្ធ គឺជាសារដ៏មានឥទ្ធិពលបំផុតនៃវិធីទំនាក់ទំនង និងការអប់រំរបស់គាត់។

លោក ផេតត្រូ ប្រូដាដូ សរសេរយ៉ាងអស្ចារ្យអំពីសមាហរណកម្មនៃមនុស្សជាតិ និងភាពបរិសុទ្ធរបស់ ដុនបូស្កូ បាននិយាយថា៖  ដុនបូស្កូ គឺជាអ្នកប្រាស្រ័យទាក់ទងក្នុងពេលវេលា ឌីជីថល និងការពិតនិម្មិតរបស់យើង។ ប្រសិនបើអតីតកាល ក្នុងចំណោមយុវជនរបស់គាត់ គាត់មានវត្តមានយ៉ាងជ្រាលជ្រៅតាមរយៈភាពជាឪពុកខាងផ្នែកអប់រំ និងការប្រាស្រ័យទាក់ទងរបស់គាត់សព្វថ្ងៃនេះ គាត់មានវត្តមាននៅក្នុងយើងម្នាក់ៗ ដែលប្រាស្រ័យទាក់ទងគ្នាយ៉ាងមានប្រសិទ្ធិភាពក្នុងជីវិតយុវវ័យហសម័យនេះ។

# ព័ត៌មានដុនបូស្កូកម្ពុជា

## កីឡាពណ៌

អបអរសាទរ ពិធីបុណ្យកីឡាពណ៌ និង ខួប ៣០ ឆ្នាំ ដុនបូស្កូកម្ពុជា ប្រារព្ធពិធីនៅថ្ងៃសុក្រ ១រោច ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី ៣០ ខែ មករា ជារៀងរាល់ឆ្នាំ សាលាបដុនបូស្កូកម្ពុជារំលឹក ខួប ២០៥ ឆ្នាំដុនបូស្កូពិភពលោក ចាប់តាំងពីឆ្នាំ ១៨១៥-២០២១ និង ខួប៣០ ឆ្នាំដុនបូស្កូ ទាំង ៤ មកដល់ប្រទេសកម្ពុជា (១៩៩១-២០២១) ដោយមានការចូលពី លោកពុក លោកគ្រូ អ្នកគ្រូ និងសិស្សនិស្សិតរួម ទាំងបុគ្គលិក ប្អូនៗមូលនិធិកុមារ និកុមារមកពីតំបន់ជុំវិញខេត្ត មក សិក្សានៅសាលាដុនបូស្កូទាំងអស់បានរួមផ្តុំគ្នាជាក្រុមៗ ដើម្បីលេកីឡា យ៉ាងសប្បាយរីករាយបាត់អស់ទុក្ខកង្វល់បន្សល់នូវស្នាមញញឹម ។


កីឡាពណ៌ដុនបូស្កូខេត្តកែប


កីឡាពណ៌ដុនបូស្កូខេត្តព្រះសីហនុ


កីឡាពណ៌ដុនបូស្កូភ្នំពេញ

## ការផ្តល់ជូនវិញ្ញាបនប័ត្រដល់និសិត្សនៅសាលាបច្ចេកទេសដុនបូស្កូ

